Biosecurity

Department of **Industry, Tourism and Trade**



# ព័ត៌មានអំពីចេកកើតជំងឺក្រា (Banana freckle)

## តើក្រាចេកជាអ្វី?

ក្រាចេក គឺជាជំងឺរុក្ខជាតិមួយប្រភេទដែលបង្កឡើងដោយពពួកផ្សិត Phyllosticta cavendishii។ ផ្សិតប្រភេទនេះមិនមាននៅប្រទេសអូស្ត្រាលីទេ ហើយវាយាយីដំណាំចេកអំបូងនិងចេកប្រភេទផ្សេងទៀត។ នៅក្រោមច្បាប់ស្តីពីសុខភាពរុក្ខជាតិនៃដែនដីខាងជើង(Northern Territory Plant Health Act) ឆ្នាំ2008 គឺគេត្រូវប្រកាសឱ្យដំណឹងបើមានការយាយីនៃជំងឺក្រាចេកនេះ។

ប្រសិនបើអ្នកសង្កេតឃើញរោគសញ្ញាគួរឱ្យសង្ស័យ អ្នកត្រូវរាយការណ៍ទៅកាន់ក្រុមការងារឆ្លើយតបថ្នាក់ជាតិស្តីពីជំងឺក្រាចេក តាមរយៈលេខ 088999 2136 ឬអ៊ីមែល BananaFreckle.NT@nt.gov.au ឬបំពេញទម្រង់នៃការផ្តល់មតិត្រលប់វិញតាមរយៈគេហទំព័ររបស់យើងខ្ញុំ។

មានការត្រួតពិនិត្យកំពុងដំណើរការនៅក្រុង ដារវិន (Darwin) និងតំបន់ជនបទនៅជុំវិញក្រុង។ គ្រប់ផ្ទះឬចម្ការទាំងអស់នៅក្នុងតំបន់ជុំវិញកន្លែងដែលគេរកឃើញជំងឺនេះ គឺត្រូវបានត្រួតពិនិត្យរកមើលដើម   ចេក។

ប្រសិនបើរកពុំឃើញមានសញ្ញាណនៃជំងឺនេះទេ នោះនឹងមិនមានការកាប់ដើមចេកចោលទេ។ សម្រាប់ព័ត៌មានបន្ថែម សូមស្កេនកូដ QR នេះ៖

ប្រសិនបើអ្នកប្រទះឃើញជំងឺនេះ សូមរាយការណ៍។

NORTHERN TERRITORY GOVERNMENT | **Biosecurity** Northern Territory



# តើត្រូវរកមើលអ្វីខ្លះ?

- ស្នាមអុជពណ៌ខ្មៅឬពណ៌ត្នោតចាស់មានទំហំផ្សេងៗគ្នានៅលើស្លឹកនិងផ្លែ
- ស្នាមអុជអាចមានលក្ខណៈជាខ្សែបង្កើតជាស្នាមឆ្នូតវែងៗ
- ស្នាមអុជមានសភាពដូចក្រដាសខាត់ដោយសារផ្សិតនោះតោងជាប់នៅលើផ្ទៃ
- លទ្ធផលនៃការឆ្លងកម្រិតខ្ពស់គឺស្លឹកពណ៌លឿង  អាចស្វិតស្រពោនហើយងាប់។

# រុក្ខជាតិដែលឆ្លងរោគនៅដែនដីខាងជើង

- ដើមចេកទាំងអស់មិនថានៅផ្ទះឬចម្ការដែលមានដើមឆ្លងមេរោគនឹងត្រូវកាប់ចោល ដោយអនុវត្តតាមការឆ្លើយតបថ្នាក់ជាតិស្តីពីជំងឺក្រាចេក (National Banana Freckle Response)។
- ផ្ទះឬចម្ការទាំងនេះនឹងមិនត្រូវអនុញ្ញាតឱ្យដាំដើមចេកវិញក្នុងរយៈពេលយ៉ាងតិច១២ខែ ជាធម្មតាគឺពេញមួយរដូវសើម និងពេញមួយរដូវរាំងស្ងួតដើម្បីធានាឱ្យបានថាមិនមានហានិភ័យនៃការរីករាលដាលនៃជំងឺនៅតាមផ្ទះឬចម្ការឡើយ។
- អ្នកលក់បន្ត អ្នកបណ្តុះកូនឈើ និងអ្នកទិញ គឺតម្រូវឱ្យរាយការណ៍ពីរោគសញ្ញាគួរឱ្យសង្ស័យដែលមានលើដើមចេក។

# ហេតុអ្វីបានជាវាមានបញ្ហា?

ជំងឺចេកក្រាគឺជាការគំរាមកំហែងធ្ងន់ធ្ងរមួយទៅលើឧស្សាហកម្មផ្លែចេក។
ជំងឺនេះបានធ្វើឱ្យសុខភាពនិងផលិតភាពរបស់រុក្ខជាតិចុះថមថយ។
ប្រសិនបើវាប៉ះពាល់គុណភាពនិងរូបរាងផ្លែហើយ
នោះមានន័យថាផ្លែដែលមានស្នាមអុជមិនអាចមានទីផ្សារឡើយ
ហើយអាចបណ្តាលឱ្យមានការឡើងថ្លៃសម្រាប់អតិថិជនទៀតផង។

ឧស្សាហកម្មផ្លែចេករបស់ប្រទេសអូស្ត្រាលីមានតម្លៃ៦០០លានដុល្លារ ដែលមានប្រជាជន ៩៦%ទិញផ្លែចេក។
ការបំបាត់ផ្សិត Phyllosticta cavendishii គឺត្រូវបានចាត់ទុកថា ជាផលប្រយោជន៍សេដ្ឋកិច្ច និងជាការចាំបាច់
ដើម្បីជៀសវាងផលប៉ះពាល់នៃការរីករាលដាលនៃជំងឺក្រាចេកនេះ ទាំងនៅក្នុងតំបន់និងក្នុងប្រទេសទាំងមូល។

# ការសាកសួរនិងព័ត៌មាន

- លក្ខណៈនៃការឆ្លើយតបតាមបែបបទជីវសន្តិសុខ មានន័យថាស្ថានភាពអាចផ្លាស់ប្តូរ យ៉ាងឆាប់   រហ័ស។ ដើម្បីទទួលព័ត៌មានបានទាន់ពេលវេលា សូមមើលគេហទំព័ររបស់យើងខ្ញុំ nt.gov.au/banana-freckle ឬក្រុមហ្វេសប៊ុកBiosecurity ដែលមានឈ្មោះ @biosecNT។
- សូមទាក់ទងក្រុមការងារនៃការឆ្លើយតបថ្នាក់ជាតិស្តីពីជំងឺក្រាចេក តាមរយៈលេខ 088999 2136 ឬអ៊ីមែល bananafreckle.nt@nt.gov.au
- ការណែនាំទូទៅសម្រាប់អ្នកដាំផ្លែឈើនិងបន្លែក្នុងដែនដីខាងជើង (Northern Territory) អាចរកបាននៅលើគេហទំព័រ nt.gov.au។